# ព្រះរាជក្រម

នស/រកម/០២០៧/០១០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៤ របស់អាស៊ានស្តីពីតម្រូវការផ្នែកបច្ចេកទេសរបស់យានយន្ត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់
# ស្ដីពី
# ការអនុម័តយល់ព្រមលើពិធីសារទី ៤ របស់
# អាស៊ានស្ដីពីតម្រូវការផ្នែកបច្ចេកទេសរបស់យានយន្ត

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារទី ៤ របស់អាស៊ានស្ដីពីតម្រូវការផ្នែកបច្ចេកទេសរបស់យានយន្ត ដែលធ្វើនៅទីក្រុងហាណូយ ប្រទេសវៀតណាម នាថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០០៧

នស/រកម.០២០៧.០០៤

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ដលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
**ហត្ថលេខា**
**ស៊ុន ចាន់ថុល**

លេខ: ៤៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
**យ៉ុន ជីនកេន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

# ពិធីសារអាស៊ាន

## ពិធីសារទី ៤

ស្តីពី

# តម្រូវការ ផ្នែកបច្ចេកទេសរបស់យានយន្ត
# TECHNICAL REQUIREMENTS OF VEHICLES

នាយកដ្ឋានផែនការ - មិថុនា ២០០២

PLANNING DEPARTMENT, JUNE 2002

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ .....០៤.....[illegible]

## សេចក្ដីថ្លែងហេតុនៃ
## សេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រម លើពិធីសារអាស៊ាន
## ស្ដីពីតម្រូវការផ្នែកបច្ចេកទេសរបស់យានយន្ត

**ក- លំនាំដើម**

នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី ៥ របស់រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១៤-១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានបានឯកភាពយល់ព្រម និងចុះហត្ថលេខា លើពិធីសារ និងកិច្ចព្រមព្រៀងចំនួន ៣ ដូចខាងក្រោម :

- ពិធីសារទី ៣ : ស្ដីពីការកំណត់ប្រភេទ និងបរិមាណយានយន្តដឹកជញ្ជូនផ្លូវគោក
- ពិធីសារទី ៤ : ស្ដីពីតម្រូវការបច្ចេកទេសរបស់យានយន្ត
- កិច្ចព្រមព្រៀងថ្នាក់រដ្ឋមន្ត្រី ស្ដីពីការអភិវឌ្ឍបណ្ដាញផ្លូវអាស៊ានហាយវេ

ពិធីសារទី ៤ នេះ ជាពិធីសារលំអិតផ្នែកបច្ចេកទេស សម្រាប់អនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្ដីអំពីការសម្រួលការដឹកទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខានៅខែ សីហា ឆ្នាំ ១៩៩៨ នៅទីក្រុងហាណូយ ប្រទេស វៀតណាម ដែលជាកិច្ចព្រមព្រៀងមួយនៅក្នុងចំណោមកិច្ចព្រមព្រៀង និងពិធីសារទាំង ២៧ របស់អាស៊ានហើយ ដែលសភាជាតិបានផ្ដល់ ...ាប័នទទួលស្គាល់រួចហើយ កាលពីឆ្នាំ ២០០០ កន្លងទៅ បន្ទាប់ពីកម្ពុជាបានចូលជាសមាជិកអាស៊ាន ។ កិច្ចព្រមព្រៀងនេះតម្រូវឱ្យប្រទេសជាសមាជិកយល់ព្រម និងចុះហត្ថលេខាលើពិធីសារចំនួន ៩ ដែលលំអិតខាងបច្ចេកទេសសម្រាប់អនុវត្តកិច្ចព្រមព្រៀង :

ពិធីសារទី ១ : ការកំណត់ទុកជាមុននៃផ្លូវ និងមធ្យោបាយ លើផ្លូវថ្នល់សម្រាប់សម្រួល ក្នុងការដឹកជញ្ជូនឆ្លងកាត់

ពិធីសារទី ២ : ការកំណត់ជាមុននៃប៉ុស្ដិ៍ត្រួតពិនិត្យតាមព្រំដែន

ពិធីសារទី ៣ :ប្រភេទ និងបរិមាណនៃយានយន្តតាមផ្លូវគោក

ពិធីសារទី ៤ : តម្រូវការខាងបច្ចេកទេសនៃយានយន្ត

ពិធីសារទី ៥ : ផែនការអាស៊ាននៃការធានារ៉ាប់រង ក្នុងកាតព្វកិច្ចទទួលខុសត្រូវរបស់យានយន្ត

ពិធីសារទី ៦ : ព្រំដែនផ្លូវដែក និងស្ថានីយប្តូរផ្លូវដែកទាំងឡាយ

ពិធីសារទី ៧ : ប្រព័ន្ធគយសម្រាប់ការឆ្លងកាត់

ពិធីសារទី ៨ : វិធានការអនាម័យ និងភូតគាមអនាម័យ

ពិធីសារទី ៩ : ទំនិញគ្រោះថ្នាក់

មានពិធីសារចំនួន ៣ ដែលបានចុះហត្ថលេខារួចហើយដោយរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន

ពិធីសារទី ៣ : ប្រភេទ និងបរិមាណនៃយានយន្តតាមផ្លូវគោក (ចុះហត្ថលេខានៅឆ្នាំ ១៩៩៩)

ពិធីសារទី ៤ : តម្រូវការខាងបច្ចេកទេសនៃយានយន្ត (ចុះហត្ថលេខានៅឆ្នាំ ១៩៩៩)

ពិធីសារទី ៩ : ទំនិញគ្រោះថ្នាក់ (ចុះហត្ថលេខាកាលពីឆ្នាំ ២០០២ និងកំពុងសុំសច្ចាប័នពីរដ្ឋសភាជាតិ)

មានពិធីសារចំនួន ០២ ទៀត បានចុះហត្ថលេខានៅចុងឆ្នាំ ២០០០ និងដើមឆ្នាំ ២០០១ ដោយក្រសួង ស្ថាប័នផ្សេងៗ :

<u>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ</u>

- ពិធីសារទី ៥ : ផែនការអាស៊ាននៃការធានារ៉ាប់រង ក្នុងកាតព្វកិច្ចទទួលខុសត្រូវរបស់យានយន្ត (ពិធីសារនេះ បានផ្តល់សច្ចាប័នរួចហើយពីរដ្ឋសភាជាតិ កាលពីឆ្នាំ ២០០២ កន្លងទៅ)

<u>ក្រសួងកសិកម្ម និងក្រសួងសុខាភិបាល</u>

- ពិធីសារទី ៨ : វិធានការអនាម័យ និងភូតគាមអនាម័យ (ពិធីសារនេះ បានផ្តល់សច្ចាប័នរួចហើយពីរដ្ឋសភាជាតិ កាលពីឆ្នាំ ២០០២ កន្លងទៅ)

មានពិធីសារ ៤ ទៀត ដែលពុំទាន់បានចុះហត្ថលេខា :

-ពិធីសារទី១: ការកំណត់ទុកជាមុនផ្លូវ និងមធ្យោបាយ លើផ្លូវផ្តល់សម្រាប់សម្រួលក្នុងការដឹកជញ្ជូនឆ្លងកាត់។ បច្ចុប្បន្នពិធីសារនេះ បានឈានចូល ដល់ដំណាក់កាលឯកភាពគ្នា នឹងចុះហត្ថលេខានៅខែ វិច្ឆិកា ឆ្នាំ ២០០៥ ក្នុងឱកាសនៃកិច្ចប្រជុំរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានលើកទី ១១ នៅទីក្រុងវៀងច័ន្ទប្រទេសឡាវ។

- ពិធីសារទី ៦ : ព្រំដែនផ្លូវដែក និងស្ថានីយប្តូរផ្លូវដែកទាំងឡាយ (ពិធីសារនេះនៅរង់ចាំចម្លើយជាចុងក្រោយពីប្រទេសសិង្ហបុរី និងអាចចុះហត្ថលេខាបាននៅឆ្នាំ ២០០៦ ខាងមុខ) រាជរដ្ឋាភិបាលបានផ្តល់សិទ្ធិ

ប្រទានរួចហើយ ជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីចុះហត្ថលេខាកាលពីឆ្នាំ ២០០១ និង ២០០៤ កន្លងទៅ ។

- ពិធីសារ ២ : ការកំណត់ជាមុននៃប៉ុស្តិ៍តាមព្រំដែន
- ពិធីសារ ៧ : ប្រព័ន្ធគយសម្រាប់ការឆ្លងកាត់

ពិធីសារទាំង ២ នេះ ជាសមត្ថកិច្ចរបស់ស្ថាប័នគយ ដែលត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ប៉ុន្តែត្រូវជាប់គាំងដោយពិធីសារទី១ : ( ការកំណត់ទុកជាមុននៃផ្លូវ និងមធ្យោបាយលើផ្លូវផ្តល់សម្រាប់សម្រួលក្នុងការដឹកជញ្ជូនឆ្លងកាត់ ) ដែលពុំទាន់អាចចុះហត្ថលេខាបាន ។

ពិធីសារទី ៤ មាន ៨ មាត្រា និងឧបសម្ព័ន្ធ ៦ ដែលបានចុះហត្ថលេខានៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ដោយរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន ។

គោលបំណងនៃពិធីសារទី៤ គឺដើម្បីកំណត់ប្រភេទ និងបរិមាណយានយន្តសម្រាប់អនុវត្តក្នុងការសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់ កំណត់កាតព្វកិច្ច ការរៀបចំស្ថាប័ន របស់ភាគីចុះកិច្ចសន្យា ឬប្រទេសជាសមាជិក និងការចូលរួមរបស់ប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ ។

I- ខ្លឹមសារសង្ខេប និងចំណុចសំខាន់ៗ

- ពិធីសារបានកំណត់និយមន័យនៃពាក្យបច្ចេកទេសសំខាន់ៗ ដែលជាតម្រូវការក្នុងការត្រួតពិនិត្យបច្ចេកទេសយានយន្ត។ ពិធីសារក៏បានកំណត់ផងដែរ អំពីទំហំនៃការប្រតិបត្តិ និងកាតព្វកិច្ច ក្នុងការអនុវត្តពិធីសារ។ យានយន្តដឹកជញ្ជូនឆ្លងកាត់ត្រូវចុះបញ្ជីជាមួយគណៈកម្មាធិការជាតិសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់រៀងៗខ្លួន ភាគីនីមួយៗ ធានាថា យានយន្តដឹកជញ្ជូនឆ្លងកាត់ ត្រូវបំពេញទៅតាមលក្ខណបច្ចេកទេស ទំហំ (បណ្តោយ-ទទឹង-កម្ពស់)
- ទម្ងន់សរុប អតិបរិមា និងបន្ទុក កម្រិតស្តង់ដា នៃការបញ្ចេញផ្សែង និងចំណុចពាក់ព័ន្ធ ដែលមានចែងក្នុងពិធីសារនេះ។ ភាគីទាំងអស់ត្រូវគិតគូអំពីស្ថានភាព បច្ចុប្បន្នរបស់ផ្លូវ និងបញ្ជាក់អំពីការតាំងចិត្តរបស់គេ ដើម្បីធ្វើឱ្យប្រសើរឡើងនូវផ្លូវដឹកជញ្ជូន ដែលពួកគេបានកំណត់គ្នា និងដែលអាចធ្វើទៅបានតាមការខិតខំប្រឹងប្រែងរបស់ខ្លួនតម្រូវទៅតាមលក្ខណបច្ចេកទេសយានយន្ត ដូចក្នុងពិធីសារនេះ
- ត្រូវយកជាប់ខ្លួនជាប្រចាំឯកសារដូចជា វិញ្ញាបនប័ត្រចុះបញ្ជី (លក្ខណៈ និងកម្មសិទ្ធិយានយន្ត) សុពលភាពវិញ្ញាបនប័ត្រ ប័ណ្ណបញ្ជាក់ការធានារ៉ាប់រងភាគីទី ៣ កំណត់នៃការប្រគល់ ឬ បញ្ជីអ្នកដំណើរ ឬ បញ្ជីកញ្ចប់ទំនិញឯកសារគយឆ្លងកាត់ សម្រាប់ទំនិញ អាជ្ញាប័ណ្ណក្រុមហ៊ុនដឹកជញ្ជូន ។ល។

- ឯកសារណាមួយមិនមានសុពលភាពនឹងមិនទទួលស្គាល់សម្រាប់អនុវត្តដោយពិធីសារនេះទេ។ រាល់ឯកសារទាំងអស់ត្រូវភ្ជាប់ការបញ្ជាក់បកប្រែជាភាសាអង់គ្លេស ។ យានយន្តដឹកជញ្ជូនឆ្លងកាត់គ្រប់ពេលវេលាត្រូវមានបិទបង្ហាញផ្លាកសញ្ញាសម្គាល់ នៃការចុះបញ្ជីពីភាគីជាប្រទេសដើមរបស់ខ្លួន
- កិច្ចប្រជុំក្រុមមន្ត្រីដឹកជញ្ជូនជាន់ខ្ពស់ គឺជាអ្នកទទួលខុសត្រូវសម្របសម្រួល ត្រួតពិនិត្យ និងធ្វើរបាយការណ៍ទៀងទាត់អំពីភាពជឿនលឿន ក្នុងការអនុវត្តពិធីសារនេះ ជូនក្រុមប្រឹក្សាសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ថ្នាក់តំបន់របស់អាស៊ាន ដោយមានការជួយទ្រទ្រង់ខាងបច្ចេកទេស និងតាមរយៈលេខាធិការដ្ឋានអាស៊ាន
- ពិធីសារនេះបានគេចុះហត្ថលេខា និងតម្កល់ទុកនៅលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកចែកផ្សព្វផ្សាយឱ្យបានរហ័សទៅគ្រប់ភាគី
- ពិធីសារនេះ និងឧបសម្ព័ន្ធរបស់វា គឺជាផ្នែកបញ្ចូលគ្នាជាមួយកិច្ចព្រមព្រៀង
- ពិធីសារនេះ ជាកម្មវត្ថុនៃការធ្វើសច្ចាប័ន ឬ ការយល់ព្រមដោយភាគីចុះកិច្ចសន្យា
- លិខិតុបករណ៍ នៃការធ្វើសច្ចាប័ន ឬការចូលត្រូវតម្កល់ទុកនៅលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកផ្សព្វផ្សាយយ៉ាងរហ័ស ទៅគ្រប់ភាគីចុះកិច្ចសន្យា
- ពិធីសារចូលជាធរមាននៅពេលលិខិតុបករណ៍ នៃការធ្វើសច្ចាប័ន ឬការសុំចូលពីគ្រប់ភាគី និងតម្កល់ទុកនៅលេខាធិការដ្ឋានអាស៊ាន
- វិសោធនកម្មនៃពិធីសារ និងឧបសម្ព័ន្ធរបស់វាអាចប្រព្រឹត្តទៅបាន តាមការព្រមព្រៀងពីគ្រប់ភាគីទាំងអស់ ។

អាស្រ័យដូចបានទូលថ្វាយ និងជម្រាបជូនខាងលើនេះ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រម លើពិធីសារអាស៊ាន ស្តីពីតម្រូវការផ្នែកបច្ចេកទេសរបស់យានយន្តនេះ ដោយអនុគ្រោះ។

រាជធានីភ្នំពេញ [illegible] ១៧ ឆ្នាំ២០០៥

ហ៊ុន សែន

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

# ពិធីសារទី ៤
# ស្តីពីតម្រូវការ ផ្នែកបច្ចេកទេសរបស់យានយន្ត

❖❖❖❖❖❖❖❖❖❖❖❖

រដ្ឋាភិបាល នៃប្រទេស ប្រ៊ុយណេ ដារូសាឡាម, ព្រះរាជាណាចក្រកម្ពុជា, សាធារណរដ្ឋឥណ្ឌូណេស៊ី, សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ, ប្រទេសម៉ាឡេស៊ី, សាធារណរដ្ឋហ្វីលីពីន, សាធារណរដ្ឋសិង្ហបុរី, ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម, គឺជារដ្ឋសមាជិក នៃសមាគមប្រជាជាតិ អាស៊ីភាគអាគ្នេយ៍ (ពីពេលនេះតទៅ ហៅកាត់ថា " ភាគីចុះកិច្ចសន្យា " )

**រំលឹកឡើងវិញ** ពីកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសំរួលទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខា នៅថ្ងៃទី 16-ធ្នូ- 1998 នៅទីក្រុងហាណូយ ប្រទេសវៀតណាម ( តទៅហៅកាត់ថាកិច្ចព្រមព្រៀង ) ។

**ទទួលស្គាល់ថា** ថាមាត្រា ១១ និង ២៥ របស់កិច្ចព្រមព្រៀង ចែងសំរាប់ការសំរេចចិត្តនូវការអនុវត្តន៍ពិធីសារទាំងឡាយដែលនឹងបង្កើតជាផ្នែករួមបញ្ចូលគ្នា របស់កិច្ចព្រមព្រៀង និងមាត្រាទាំងឡាយរបស់វា ។

**រំលឹកឡើងវិញបន្ថែម** នូវផែនការសកម្មភាព ទីក្រុងហាណូយ ដែលបានយល់ព្រមដោយបណ្តាប្រមុខរដ្ឋ និងរដ្ឋាភិបាលអាស៊ាន នៅឯកិច្ចប្រជុំកំពូលអាស៊ានលើកទី ៦ នៅទីក្រុងហាណូយ ប្រទេសវៀតណាម នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ ដែលចែងអោយធ្វើការប្រតិបត្តិ កិច្ចព្រមព្រៀងនៅឆ្នាំ ២០០០ ។

**បច្ចុប្បន្នដោយហេតុដូចនោះ បណ្តាភាគីចុះកិច្ចសន្យា បានព្រមព្រៀងគ្នាដូចខាងក្រោម :**

## មាត្រាទី ១
## និយមន័យ

សំរាបបំរើអោយគោលបំណង នៃពិធីសារនេះ :

ក-"Transit Transport/ការដឹកជញ្ជូនឆ្លងកាត់ " ត្រូវមានអត្ថន័យដូចដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង ។

ខ-"RoadTransit Transport Vehicles/ រថយន្តដឹកជញ្ជូនឆ្លងកាត់លើផ្លូវគោក " ត្រូវមានអត្ថន័យដូចដែលបានកំណត់នៅ ក្នុងពិធីសារទី ៣ ។

01/09/99 Protocol-3
ពង្រាងបញ្ចប់លើកទី ១

ឃ- Protocol 3 / ពិធីសារទី ៣ " មានន័យថា ពិធីសារទី ៣ ស្តីពីប្រភេទនិងបរិមាណយានយន្តផ្លូវគោក អនុលោម ទៅតាមកិច្ចព្រមព្រៀង ។

ឃ- "Wheelbase/ ចំងាយចន្លោះភ្លៅនៃកង់រថយន្ត " មានន័យថា ចំងាយរវាង ខ្សែបន្ទាត់កណ្តាលនៃភ្លៅកង់មុខ ( First Axle ) និងចំនុចកណ្តាលរបស់ភ្លៅកង់ក្រោយផ្តិតគ្នារបស់រថយន្តរឹងគ្មានតំណដែលមានភ្លៅ ៣ ជួរ " Three Axle Rigid Motor Vehicle " ។

ង- " Maximum Permissible Gross Vehicle Weight / ទំងន់យានយន្តសរុបអតិបរិមា ដែលអាចអនុញ្ញាតអោយ " មានន័យថា ជាទំងន់អតិបរិមាដែលអនុញ្ញាតរបស់រថយន្ត ដោយគិតទាំងទំងន់អ្នកបើកបរ មនុស្សទាំងអស់ និងទំងន់ឥវ៉ាន់សរុប ឬ បន្ទុកនៅលើរថយន្តដែលសង្កត់បញ្ជូន ទៅលើផ្លូវថ្នល់តាមរយៈកង់របស់វាទាំងអស់ ។

## មាត្រាទី ២
## ទំហំនៃការអនុវត្តន៍

អនុលោមទៅតាមប្រការ ១១ នៃកិច្ចព្រមព្រៀង. ភាគីចុះកិច្ចសន្យាទាំងឡាយតាមរយៈនេះ យល់ព្រមធ្វើតាម ( ឬ បំពេញតាម ) បទប្បញ្ញត្តិទាំងឡាយ នៃពិធីសារនេះ ទៅលើយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក ដែលចូលរួមក្នុងការដឹកជញ្ជូនឆ្លងកាត់ ។

## មាត្រាទី ៣
## ភារកិច្ច

១- ភាគីចុះកិច្ចសន្យាត្រូវធានាថា យានយន្តដឹកជញ្ជូនឆ្លងកាត់និមួយៗ ត្រូវតែបានគេចុះបញ្ជីជាមួយនឹង គណៈកម្មាធិការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់រៀងខ្លួនៗ ( គជសដឆ ) ដែលអ្នកប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ទាំងនោះបានចុះបញ្ជី ស្របទៅតាម ពិធីសារទី ៣ ។

២- ភាគីចុះកិច្ចសន្យា ត្រូវធានាថាយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោកនិមួយៗ បំពេញទៅតាមតំរូវការខាងបច្ចេកទេស ទៅតាមទំហំ( បណ្តោយ ទទឹង កំពស់ )នៃយានយន្ត ទំងន់សរុបអតិបរិមា និងបន្ទុកក្រិតស្តង់ដារនៃការបញ្ចេញផ្សែង និងចំណុចពាក់ព័ន្ធទាំងឡាយដែលបានអធិប្បាយលំអិត នៅក្នុងពិធីសារនេះ ។

01/09/99 Protocol-3
ពង្រាងបញ្ចប់លើកទី ១

## មាត្រាទី ៤
## តម្រូវការខាងបច្ចេកទេសជាចាំបាច់

១- យានយន្តដឹកជញ្ជូនឆ្លងកាត់លើផ្លូវគោក ដោយបំពេញតាមពិធីសារនេះ មិនត្រូវបានគេអនុញ្ញាតអោយចូលរួម សំរាប់ការដឹកជញ្ជូនឆ្លងកាត់ទេ លើកលែងតែតំរូវការខាងបច្ចេកទេស ដូចខាងក្រោមនេះត្រូវបានគេបំពេញ :

ក- ទំហំយានយន្តអតិបរិមាពោលគឺ : ( Maximum Vehicle Dimension )

ក-១ ប្រវែងបណ្តោយរថយន្តអតិបរិមា ដូចដែលបានលំអិតក្នុងឧបសម្ព័ន្ធ A & B

ក-២ ប្រវែងទទឹងរថយន្តអតិបរិមា ដូចដែលបានលំអិតក្នុងឧបសម្ព័ន្ធ C

ក-៣ កំពស់រថយន្តអតិបរិមា ដូចដែលបានលំអិតក្នុងឧបសម្ព័ន្ធ D

ក-៤ " កន្ទុយក្រោយ " ដែលភាសាអង់គ្លេសហៅថា Rea Overhang (ROH) " ប្រវែងពីចំនុចកណ្តាល នៃចង្កោមភ្លៅកង់ក្រោយ ទៅចំនុចក្រោយបំផុតនៃកន្ទុយយាន " ដូចដែលបានលំអិតក្នុងឧបសម្ព័ន្ធ E

ខ- ទំងន់សរុបអនុញ្ញាតអតិបរិមា ដូចដែលបានលំអិតក្នុងឧបសម្ព័ន្ធ F

គ- ស្តង់ដារ នៃការបញ្ចេញផ្សែងដូចខាងក្រោម ( Emission Standards ) :
ការបញ្ចេញឧស្ម័នចោល( ផ្សែង)៥០ ٪ ( អូប៉ាស៊ីធី (Opacity) ឬក៏ទៀនបញ្ឆេះ-ប៊ូស្សិ៍ (Bosh) ឬ ៥០ HSU និង

ឃ- តំរូវការពាក់ព័ន្ធផ្សេងៗ ដូចជា :

ឃ-១ ប្រសិទ្ធិភាពហ្វ្រាំង : 50٪ នៃទំងន់របស់ភ្លៅ និង

ឃ-២ ភាពរអិលចេញពីផ្លូវ : បូក ( + ) ឬ ដក ( - ) ៥ ម/គម

២- ភាគីចុះកិច្ចសន្យា យល់ព្រមដាក់កំរិតស្តង់ដារ តំរូវការបច្ចេកទេសខាងលើ សំរាប់ពិធីសារនេះ ប៉ុន្តែតំរូវការ គិតគូរពិចារណា អំពីស្ថានភាពបច្ចុប្បន្នរបស់ផ្លូវ នៃបណ្តាប្រទេសសមាជិកមួយចំនួនវាត្រូវបានគេយល់ព្រមថា ជាកិច្ចការព្រមព្រៀងចាំបាច់ ត្រូវបានរៀបចំឡើង ដើម្បីអោយមានការចូលរួមក្នុងការកត់ត្រា កែសំរួល ពត៌មានដែលជាប់ពាក់ព័ន្ធ ក្នុងការកំណត់ផ្លូវដឹកជញ្ជូនជាដំណាក់ៗ រវាងបណ្តាប្រទេសជាសមាជិក និងសមស្រប

ទៅតាមយានយន្តតែប៉ុណ្ណោះ ដែលសមរម្យទៅតាមស្ថានភាពផ្លូវទាំងនោះនៅក្នុងដំណាក់កាលដំបូងទាំងឡាយ នៃការអនុវត្តន៍ ពិធីសារនេះ ។ នៅពេលជាមួយគ្នានេះ ភាគីចុះកិច្ចសន្យា ត្រូវបញ្ជាក់សំអាងអំពីការសំរេចចិត្ត របស់ពួកគេ ដើម្បីធ្វើអោយប្រសើរឡើងនូវផ្លូវដែលបានកំណត់របស់ពួកគេ ទៅតាមការខិតខំប្រឹងប្រែងដែល អាចធ្វើទៅបាន ដើម្បីតំរូវទៅតាមយានយន្តជាមួយ នឹងតំរូវការបច្ចេកទេសដូចខាងលើ ។

## មាត្រាទី ៥

## ឯកសារ

១- ឯកសារទាំងឡាយដូចខាងក្រោម ត្រូវបានគេយកជាប់តាមយានយន្តដឹកជញ្ជូនឆ្លងកាត់លើផ្លូវគោកមួយ នៅ គ្រប់ពេលវេលាទាំងអស់ នៅពេលដែលវាស្ថិតនៅក្នុងដែនដី នៃភាគីជាប់កិច្ចសន្យាជាប់ពាក់ព័ន្ធ ដែលការដឹក ជញ្ជូនឆ្លងកាត់ ធ្វើឡើងកាត់តាមទឹកដី នៃភាគីចុះកិច្ចសន្យានោះ :

ក- វិញ្ញាបនប័ត្រចុះបញ្ជីយានយន្ត ដែលមានចុះលក្ខណៈពិសេសៗនៃយានយន្ត និងម្ចាស់កម្មសិទ្ធិ

ខ- សុពលភាពវិញ្ញាបនប័ត្រនៃការត្រួតពិនិត្យយានយន្ត

គ- ការបញ្ជាក់ធានារ៉ាប់រងទទួលខុសត្រូវនៃភាគីទី ៣ ទៅលើយានយន្ត

ឃ- កំណត់ការប្រគល់ / បញ្ជីអ្នកដំណើរ ឬ កញ្ចប់ទំនិញ

ង- ឯកសារគយឆ្លងកាត់ សំរាប់ទំនិញ និង

ច- អាជ្ញាប័ណ្ណក្រុមហ៊ុនដឹកជញ្ជូន

២- រាល់បណ្តាឯកសារដែលបានកត់សំគាល់ខាងលើ ត្រូវតែផល់អត្ថិភាពសំរាប់ការត្រួតពិនិត្យនៅពេលមានសំណើរ ដោយអាជ្ញាធរពាក់ព័ន្ធទាំងឡាយ នៃភាគីជាប់កិច្ចសន្យា ដែលការដឹកជញ្ជូនឆ្លងកាត់ធ្វើឡើងកាត់តាមទឹកដី នៃភាគីនោះ ។

៣- ឯកសារណាមួយដែលគេបាន កំណត់ថាមិនមានសុពលភាពដោយអាជ្ញាធរ ឬ ភ្នាក់ងារទាំងឡាយមានការចាត់ តាំង នៃភាគីចុះកិច្ចសន្យានោះ ឬ ដោយជនណាម្នាក់ដែលទទួលការអនុញ្ញាត ឬ ផ្តល់អាជ្ញាប័ណ្ណដោយភាគី ចុះកិច្ចសន្យា ឬ ប្រែជាមិនមានសុពលភាព អនុលោមទៅតាមច្បាប់ទាំងឡាយ នៃភាគីចុះកិច្ចសន្យា ដែលបាន ចេញឯកសារ ឬ ការពន្យានោះមិនត្រូវបានគេទទួលស្គាល់សំរាប់អនុវត្តពិធីសានេះទេ ។

ពង្រាងបញ្ចប់លើកទី ១

៤- ឯកសារណាមួយប្រសិនជាមិនមែនសរសេរជាភាសាអង់គ្លេស ត្រូវភ្ជាប់មកជាមួយនូវឯកសារបកប្រែបញ្ជាក់ជាភាសាអង់គ្លេសចេញដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ។

## មាត្រាទី ៦
## សញ្ញាគំនូសសំគាល់សមរម្យ

យានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោកមួយ ត្រូវបង្ហាញអោយឃើញនៅផ្នែកខាងក្រោយ នៃយានយន្ត នៅគ្រប់ពេលវេលាទាំងអស់ នៅពេលដែលស្ថិតនៅក្នុងទឹកដីនៃភាគីចុះកិច្ចសន្យាដទៃទៀត នូវផ្លាកសញ្ញាដែលអាចបិទភ្ជាប់បានទាំងឡាយដែលជាតំណាងអោយគ្រឿងសំគាល់ ដែលមានការទទួលស្គាល់និងការកំណត់ជាអន្តរជាតិ របស់ភាគីចុះកិច្ចសន្យាដែលយានយន្តត្រូវបានគេចុះបញ្ជីជាមួយ ។

## មាត្រាទី ៧
## ការរៀបចំស្ថាប័ន

១- កិច្ចប្រជុំរបស់មន្ត្រីដឹកជញ្ជូនជាន់ខ្ពស់អាស៊ាន ត្រូវតែជាអ្នកទទួលខុសត្រូវសំរាប់ការ ត្រួតពិនិត្យ តាមដាន ពិនិត្យមើលឡើងវិញ សំរបសំរួល និងត្រួតត្រាមើល នូវទិដ្ឋភាពទាំងអស់ពាក់ព័ន្ធទៅនឹងការប្រតិបត្តិដ៏មានប្រសិទ្ធិភាព នៃពិធីសារនេះ ។

២- កិច្ចប្រជុំរបស់មន្ត្រីដឹកជញ្ជូនជាន់ខ្ពស់អាស៊ាន ត្រូវដាក់ស្នើតាមរយៈលេខាធិការដ្ឋានអាស៊ាន របាយការណ៍ជាទៀងទាត់ នូវភាពជឿនលឿន នៃការប្រតិបត្តិពិធីសារនេះ ទៅក្រុមប្រឹក្សាភិបាលសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ ដែលបានបង្កើតឡើងអនុលោមទៅតាមមាត្រាទី 29.2 នៃកិច្ចព្រមព្រៀងសំរាប់សកម្មភាពនានាបន្ថែមទៀត ។

៣- លេខាធិការដ្ឋានអាស៊ានត្រូវផ្តល់នូវការទ្រទ្រង់ និងជំនួយខាងបច្ចេកទេស ទៅដល់កិច្ចប្រជុំ របស់មន្ត្រីដឹកជញ្ជូនជាន់ខ្ពស់ អាស៊ាន ក្នុងមុខការ និងការទទួលខុសត្រូវរបស់គេ ដូចដែលមានចែងក្នុងពិធីសារនេះ ។

## មាត្រាទី ៨
## អទេសានប្បញ្ញត្តិ

១- ពិធីសារនេះនឹងត្រូវបានគេតំកល់ទុកនៅអគ្គលេខាធិការអាស៊ាន ដែលជាអ្នកផ្សព្វផ្សាយជាបន្ទាន់ នូវច្បាប់ចំលងមួយ ដែលមានបញ្ជាក់ដូចគ្នានេះ ទៅភាគីចុះកិច្ចសន្យាទាំងអស់ ។

01/09/99 Protocol-3
ពង្រាងបញ្ចប់លើកទី ១

២- ពិធីសារនេះ និងឧបសម្ព័ន្ធទាំងឡាយរបស់វានឹងបង្កើតឡើងបានជាផ្នែកមួយរួមបញ្ចូលគ្នាជាមួយកិច្ចព្រមព្រៀង

៣- ពិធីសារនេះ គឺជាកម្មវត្ថុក្នុងការធ្វើសច្ចាប័ន ឬ ការយល់ព្រមដោយភាគីចុះកិច្ចសន្យា លិខិតតុបករណ៍នៃការធ្វើសច្ចាប័ន ឬ ការយល់ព្រមត្រូវគេតំកល់ទុកនៅជាមួយនឹងអគ្គលេខាធិការអាស៊ាន ដែលជាអ្នកផ្ដល់ពត៌មានយ៉ាងរហ័សទៅភាគី ចុះកិច្ចសន្យានិមួយៗ នូវការតំកល់ទុកនេះ ។

៤- ពិធីសារនេះនឹងត្រូវចូលជាធរមាននៅពេលណាដែលការតំកល់ទុកនូវលិខិតតុបករណ៍ នៃការធ្វើសច្ចាប័ន ឬ ការយល់ព្រម ធ្វើឡើងពីគ្រប់ភាគីចុះកិច្ចសន្យាទាំងអស់ នៅអគ្គលេខាធិការអាស៊ាន ។

៥- ការធ្វើវិសោធនកម្មណាមួយទៅលើប្រការទាំងឡាយ ដែលមានចែងក្នុងពិធីសារនេះ និងឧបសម្ព័ន្ធទាំងឡាយរបស់វាសំរេចទៅបានតាមរយៈការព្រមព្រៀងគ្នា ពីគ្រប់ភាគីចុះកិច្ចសន្យាទាំងអស់ ។

ជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម ដែលបានទទួលសិទ្ធប្រទានយ៉ាងត្រឹមត្រូវ ដើម្បីចុះហត្ថលេខាពីរដ្ឋាភិបាលរបស់ពួកគេទាំងឡាយរៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារទី ៤ ស្ដីពីតម្រូវការបច្ចេកទេសយានយន្ត ដើម្បីអនុវត្តកិច្ចព្រមព្រៀង ស្ដីពីការសំរួលទំនិញឆ្លងកាត់ ។

ធ្វើនៅ ទីក្រុងហាណូយ, វៀតណាម នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ ជាច្បាប់ទោលតែមួយគត់ សរសេរជាភាសារអង់គ្លេស ។

..............................................................

PENIN DATO HAJI ZAKARIA SULAIMAN

រដ្ឋមន្ត្រីគមនាគមន៍

ប្រ៊ុយណេដារូសាឡាម

..............................................................

KHY TAINGLIM

រដ្ឋមន្ត្រីសាធារណការ និងដឹកជញ្ជូន

ព្រះរាជាណាចក្រកម្ពុជា

..............................................................

ANWAR SUPRIJADI

អគ្គលេខាធិការ ក្រសួងគមនាគមន៍

សាធារណរដ្ឋឥណ្ឌូនេស៊ី

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

.................................................................
PHAO BOUNNAPHOL
រដ្ឋមន្ត្រីគមនាគមន៍, ដឹកជញ្ជូន, ប្រៃសណីយ៍ និងសំណង់
សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

.................................................................
DATO' SERI DR. LING LIONG SIK
រដ្ឋមន្ត្រីដឹកជញ្ជូន
ម៉ាឡេស៊ី

.................................................................
MAJ GEN HLA MYINT SWE
រដ្ឋមន្ត្រីដឹកជញ្ជូន
សហភាពមីយ៉ាន់ម៉ា

.................................................................
VICENTE C. RIVERA. JR.
រដ្ឋលេខាធិការ ដឹកជញ្ជូន និងគមនាគមន៍
សាធារណរដ្ឋហ្វីលីពីន

.................................................................
YEO CHEOW TONG
រដ្ឋមន្ត្រីគមនាគមន៍ និងបច្ចេកវិទ្យាពត៌មាន
សាធារណរដ្ឋសិង្ហបុរី

.................................................................
SUTHEP THAUGSUBAN
រដ្ឋមន្ត្រីដឹកជញ្ជូន និងគមនាគមន៍
ព្រះរាជាណាចក្រថៃឡង់ដ៍

.................................................................
LE NGOC HOAN
រដ្ឋមន្ត្រីដឹកជញ្ជូន
សាធារណរដ្ឋសង្គមនិយមវៀតណាម